ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម

លេខ:២៦៣៨...PC.អក

សេចក្តីជូនដំណឹង
ស្តីពី

ការអញ្ជើញចូលរួមដេញថ្លៃ ការងារចាក់បេតុងដៃកផ្លូវកម្រាស់ 0.15m ទំហំ 970m^2, ចាក់បេតុងដៃកទីធ្លា កម្រាស់ 0.1m ទំហំ 200m^2, ធ្វើស្លាកសញ្ញាឡូហ្គោ និងក្រាលការ៉ូឡាចិញ្ចើមផ្លូវនៅសាខាកំពង់ត្រាច, សាងសង់របងមានជន្លល់បង់បាញ់ប្រវែង 290m នៅទីតាំងដីសម្រាប់ដាក់បង្គោលភ្លើង ជូន អគ្គិសនីកំពត

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការងារចាក់បេតុងដៃកផ្លូវកម្រាស់ 0.15m ទំហំ 970m^2, ចាក់បេតុងដៃកទីធ្លាកម្រាស់ 0.1m ទំហំ 200m^2, ធ្វើស្លាកសញ្ញាឡូហ្គោ និងក្រាលការ៉ូឡាចិញ្ចើមផ្លូវនៅសាខាកំពង់ត្រាច, សាងសង់របងមានជន្លល់បង់បាញ់ប្រវែង 290m នៅទីតាំងដីសម្រាប់ដាក់បង្គោលភ្លើង ជូន អគ្គិសនីកំពត ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៥ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 092 652 357 និង Website : www.edc.com.kh) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០២៥ វេលាម៉ោង ១៤:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើវេលាម៉ោង ១៥:00 ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០២៥ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានចំតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ៣ ៨ ១៩ ខែ ៧ ៨ ៩ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២៥
ប្រធានគណៈកម្មាធិការលទ្ធកម្ម

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ